


ដំណើររាប់តាំងពីកើតរហូតដល់ស្លាប់ទៅវិញ យើងត្រូវប្រាស្រ័យទាក់ទងនឹងមនុស្សជាច្រើននាក់ណាស់។ ម្នាក់ហើយម្នាក់ទៀតៗ មនុស្សម្នាចេះតែដើរចូលមកពាក់ព័ន្ធនឹងជីវិតរបស់យើង ហើយខ្លួនយើងផ្ទាល់ ក៏ចេះតែមានហេតុផល តម្រូវឱ្យយើងត្រូវដើរចូលទៅពាក់ព័ន្ធនឹងជីវិតរបស់មនុស្សជុំវិញផងដែរ។ ខ្លះក៏ចូលមកលេងជាមួយយើងបានតែមួយភ្លែត ហើយក៏ទៅបាត់។ ខ្លះលឹបលៗ ចេញចូលៗម្តងបាត់ ម្តងឃើញ។ ខ្លះក៏ចូលមកបែបមែនទែនយូរ មិនមែនលេងៗ ហើយខ្លះទៀតនៅរួមជាមួយយើង រហូតដល់ថ្ងៃលាចាកលោកនេះទៅតែរៀងៗខ្លួន។ អ្នកទាំងនោះហើយជាមិត្តរួមលោកជាមួយយើង។ មិនត្រឹមតែប៉ុណ្ណឹងទេ សូម្បីតែមនុស្សម្នាដែលយើងមិនបានជួបស្គាល់ក៏ដោយ ក៏ពួកគេទាំងនោះជាមិត្តរួមជំនាន់កើតជាមួយយើង ជាមិត្តរួមលោកនេះជាមួយយើងដែរ។

គ្រាន់តែបើកភ្នែក បើកមាត់យំង៉ា ពីពោះម៉ែមកភ្លាម យើងមានឪពុកម្តាយ យើងមានបងប្អូនបង្កើតប្រុសស្រី យើងមានសាច់ញាតិដទៃៗទៀតជាច្រើន។ អ្នកទាំងនោះ មិនត្រឹមតែជាមិត្តរួមជំនាន់កើតជាមួយយើងទេ តែពួកគេ គឺជាក្រុមគ្រួសាររបស់យើង។ ជាទូទៅយើងមានក្រុមគ្រួសារ យើងចែករំលែកនូវសុខទុក្ខ និង សុភមង្គលតែក្នុងរង្វង់ក្រុមគ្រួសាររបស់យើង។ មនុស្សអាត្មានិយម គេបញ្ចប់ទំហំបេះដូងរបស់គេនៅត្រឹមរង្វង់នេះឯង ហើយមានខ្លះមិនទាំងបើកបេះដូងទៅដល់បងប្អូនសាច់ញាតិផងទេ បេះដូងរបស់គេច្រក បានត្រឹមប្តីប្រពន្ធកូនរបស់គេតែប៉ុណ្ណោះ មិនបានច្រកដល់ឪពុកម្តាយ បងប្អូនបង្កើត ប្រុសស្រីរបស់គេផង តែក៏មានខ្លះ អាចពង្រីកទៅដល់សាច់ញាតិឆ្ងាយៗខ្លះ។

យើងចាប់ផ្តើមឈានជើងចូលក្នុងសង្គមដំបូង គឺពេលយើងនៅក្នុងសាលារៀន។ តាំងពីបឋមសិក្សា រហូត

ដល់បញ្ចប់ការសិក្សា យើងបានជួបជាមួយមិត្តរួមថ្នាក់ រួមសាលាពីរាប់រយ ដល់រាប់ពាន់នាក់ សឹងតែរាប់ម៉ឺននាក់ចំពោះមនុស្សខ្លះ។ ពួកគេគឺជាមិត្តភក្តិរបស់យើង។ ពិតជាជាពិរោះណាស់ពាក្យថា មិត្តភក្តិ! យើងអាចញញឹម និងអាចសើចបាន ពេលនឹកឃើញដល់ពួកគេ។ ក្នុងវ័យសិក្សា យើងបានចែករំលែកនូវការសប្បាយរីករាយ និងទុក្ខកង្វល់របស់យើង តាមបែបជីវិតក្នុងវ័យសិក្សាជាមួយគ្នា។ មិត្តខ្លះក៏បានបញ្ចប់ទំនាក់ទំនង ពេលឈានចេញផុតពីរបងសាលា ឯខ្លះបានក្លាយជាជាដៃគូបនភឿន រួមស៊ី រួមផឹក ដើរលេងជាមួយគ្នាតាមបែបជីវិតយុវវ័យ ដែលមិនដឹងត្រជាក់ក្តៅ។ ខ្លះបានក្លាយជាមិត្តសំលាញ់រួមសុខ រួមទុក្ខ ចែករំលែកមនោសញ្ចេតនាជាមួយគ្នា ទោះបីជាពួកគេ បានចាកចេញពីរបងសាលាយូរណាស់ហើយ ក៏ដោយ គឺមានមិត្តភក្តិខ្លះ ដែលយើងស្រលាញ់រាប់អានធ្លាប់ដេញទាត់គ្នាតាំងពីវ័យក្មេង និងនៅតែបន្តរក្សាទំនាក់ទំនងជាមួយគ្នា ទោះជាម្នាក់ៗមានគ្រួសារមានកូន មានចៅរៀងៗខ្លួនហើយក៏ដោយ ក៏ទំនាក់ទំនងរបស់គេ នៅតែបន្តរហូតដល់ពួកកូនៗរបស់គេ ក៏រាប់អានគ្នាធ្វើជាមិត្តភក្តិបន្ត ដូចដែលជំនាន់ឪពុកម្តាយរបស់គេស្រលាញ់រាប់អានគ្នាដែរ។ នោះគឺ "អាពួកម៉ាករបស់យើង"។ យើងហៅគ្នាតែបែបនេះ ទាំងស្រីទាំងប្រុស តាំងតែពីសក់ខ្មៅដល់សក់សរៀងៗខ្លួន។ ពិរោះខ្លាំងណាស់ពាក្យថា អាពួកម៉ាកនេះ!

នៅកន្លែងធ្វើការ យើងមានមិត្តរួមការងារ ជាមួយជាច្រើននាក់ទៀត។ ប៉ុន្តែពួកគេមានឈ្មោះត្រឹមតែជា មិត្តរួមការងារតែប៉ុណ្ណោះ បើការងារនោះជាការងារដែលយើងចេះតែធ្វើៗទៅ ដើម្បីបានត្រឹមកម្រៃចិញ្ចឹមជីវិត ឬក៏ដើម្បីបានត្រឹមតែប្រាក់ ដោយការងារនោះមិនបានបម្រើនូវឧត្តមគតិរបស់យើងទេ។ គេជួបគ្នា ធ្វើជាមិត្តនឹងគ្នាតែពេលម៉ោងការងារ ផុតម៉ោងការងារ គឺបែកគ្នាទៅរៀងៗខ្លួនហើយ។ មិត្តរួមការងារខ្លះ សេពគប់រាប់អាន តែពេលដែលអាចទាញយកប្រយោជន៍ពីគ្នាបានតែប៉ុណ្ណោះ បើកាលណាយើងមិនអាចរកប្រយោជន៍ឱ្យគេបានទៀតទេ នោះគេចែកផ្លូវគ្នាហើយ។

ផ្ទុយទៅវិញ បើជាមិត្តរួមឧត្តមគតិវិញ គឺវាលើសពីនេះ។ ការងារដើម្បីអ្នកដទៃទាំងអស់ មិនសុទ្ធតែជាការងារបម្រើឧត្តមគតិឡើយ តែគ្រប់ការងារបម្រើឧត្តមគតិទាំងអស់ គឺសុទ្ធតែដើម្បីអ្នកដទៃ។ មិត្តភក្តិបែបនេះ ជ្រាលជ្រៅជាងមិត្តភក្តិរួមការងារ ដែលដើម្បីបានតែកម្រៃ ដើម្បីតែប្រាក់ឆ្ងាយណាស់។ ដោយហេតុថា មិត្តរួមឧត្តមគតិភាគច្រើន សុទ្ធតែជាមនុស្សដែលមានបេះដូងធំៗ អាចប្រកមនុស្សបានលើសពីរង្វង់ព្រំដែនក្រុមគ្រួសាររបស់ខ្លួន ទើបបេះដូងរបស់មិត្តរួមឧត្តមគតិ អាចប្រកគ្នាទៅវិញទៅមកបាន។

បើនិយាយរាងអួតបន្តិច គេសើចក៏សើចចុះ គឺមនុស្សបែបពួកយើងនេះ មិនបានសំបូរកៀរហ្នឹងដើងទេ។ ដើររកគ្នាបួនដប់ឆ្នាំហើយ ទើបតែរកបានប៉ុន្មាននាក់តែប៉ុណ្ណោះ វាពិតជាភ័ព្វសំណាងខ្លាំងណាស់ ដែលពួកយើងមានការងារឧត្តមគតិរួមគ្នាបែបនេះ។ មិនថាម្នាក់ៗមានឈាមក្នុងក្រុមឈាមណាឡើយ។ ក្រុមអេ ក្រុមបី ក្រុមបីបូក ឬក៏ក្រុមអូឡើយ ប៉ុន្តែបើសម្រក់

ឈាមទឹកចិត្ត ដែលស្រក់ពីបេះដូងរបស់ពួកយើងនោះ ឈាមរបស់ពួកយើង វារលាយចូលគ្នាបាន។ បានន័យថា នោះជាប្រភេទឈាមស៊េរីតែមួយ ក្រុមតែមួយ ទើបវាអាចរលាយចូលគ្នាបែបនេះបាន។

នៅក្នុងប្រទេស ដែលមិនសមគួរនឹងរស់នៅដូចជាប្រទេសយើងសព្វថ្ងៃ មិត្តរួមឧត្តមគតិមានមិនជាច្រើនប៉ុន្មានទេ យូរៗយើងអាចរកឃើញគ្នាមួយ ដែលធ្វើឱ្យយើងរំភើបរីករាយសឹងតែស្ទុះទៅឱបគ្នា! ក្នុងចិត្តគិតត្រឹមថា នោះគឺបងប្អូនខ្ញុំ! នោះគឺបងប្អូនខ្ញុំ! មិត្តភក្តិនៅក្នុងក្រុមនេះ ជាប្រភេទមិត្តដែលសំបូរហូរហៀរទៅដោយមនោសញ្ចេតនា ដែលពួកយើងអាចចែករំលែកទៅដល់មនុស្សជុំវិញ ទៅដល់ជនរួមជាតិ ហើយអ្នកដែលមានទំហំបេះដូងធំមែនទែន គឺវាហូរហៀរទឹកទៅដល់មិត្តរួមលោកនេះទាំងមូលតែម្តង។

មិត្តភក្តិរួមការងារឧត្តមគតិ ជាមិត្តដែលងាយយល់ចិត្តគ្នា ដោយឈរលើឧត្តមគតិតែមួយ ពួកយើងហាក់បីដូចជាស្គាល់គ្នា តាំងតែពីមិនទាន់បានឃើញមុខគ្នាទៅទៀត។ ពួកយើងហាក់យល់ចិត្តគ្នា និងមានអារម្មណ៍ស្និទ្ធស្នាល ធាប់យល់ពីគ្នាក្នុងដំណើរដើម្បីទៅធ្វើការងារ បម្រើឧត្តមគតិដើម្បីមនុស្សជាតិ ហើយពួកយើងតែងតែលើកទឹកចិត្តគ្នា តែងតែជួយមើលថែមើលខុសត្រូវគ្នា ជួយការពារគ្នាទៅវិញទៅមក ដើម្បីឈានទៅសម្រេចបុព្វហេតុជីវិត ដែលពួកយើងបានកំណត់សម្រាប់ខ្លួនផ្ទាល់ ថ្វីត្បិតថាម្នាក់ៗកំណត់រៀងៗខ្លួនដោយឡែកៗពីគ្នាក៏ដោយ តែដោយសារតែជាប្រភេទមនុស្សដែលនៅក្នុងក្រុមឈាមឧត្តមគតិ តែមួយជាមួយគ្នា ទើបបុព្វហេតុជីវិតទាំងនោះមានចំណុចត្រួតស៊ីគ្នាច្រើន។

អ្វីទាំងនេះ គ្រាន់តែជាប្រភេទនៃមិត្តភក្តិទូទៅ ដែលយើងអាចកត់សម្គាល់ឃើញតែប៉ុណ្ណោះ។ ក៏ប៉ុន្តែមនុស្ស ជាសត្វដែលអាចរស់នៅបាន អាស្រ័យដោយលំហូរនៃមនោសញ្ចេតនា មនុស្សរស់នៅបានដោយសារតែការទទួលយក និងការចែករំលែកនៃមនោសញ្ចេតនារវាងគ្នានឹងគ្នា។ នោះគឺមិត្តរួមមនោសញ្ចេតនា! វាជាទិដ្ឋភាពគួរឱ្យខ្លោចផ្សារខ្លាំងណាស់ ដែលមនុស្សម្នាក់មិនមាន និងមិនអាចរកបានមិត្តម្នាក់ដែលគេអាចធ្វើលំហូរមនោសញ្ចេតនាជាមួយបាន។ យើងតែងតែស្វះស្វែងរកមិត្តល្អ មិត្តពិត មិត្តស្មោះត្រង់ មិត្តយល់ចិត្ត ដែលយើងស្រលាញ់ស្មោះអស់ពីចិត្តពីថ្លើម តែតើទៅរកមិត្តប្រភេទនោះនៅឯណាឃើញទៅម្ចាស់ថ្លៃ? បើកាលណាយើងរកមិនឃើញមិត្តប្រភេទនេះ នៅក្នុងបេះដូងរបស់យើងផ្ទាល់ទេ ទោះជាវេចបង្វិចដើររកសឹកជើងដល់ត្រឹមក្បាលជង្គង់ ក៏មិនអាចរកមិត្តរួមមនោសញ្ចេតនាឃើញនោះដែរ គឺលុះត្រាតែយើងខ្លួនឯងនេះតែម្តង ជាមិត្តប្រភេទនោះជាមុនសិន នោះទើប យើងអាចមានលក្ខណសម្បត្តិគ្រប់គ្រាន់ទៅស្វែងរកមិត្តប្រភេទនោះបាន។ យើងយល់ថាគួរឱ្យអាណិតខ្លាំងណាស់ ដែលយើងមានមនុស្សនៅជុំវិញជាច្រើន តែបែរជារកមិនបានមិត្តរួមមនោសញ្ចេតនាសូម្បីតែម្នាក់។ ទស្សនវិទូម្នាក់បាននិយាយថា "លុះត្រាតែឈានចូលដល់វ័យចាស់ ទើបដឹងថាមានមិត្តធម្មតារយពាន់ម៉ឺននាក់ ប្រៀបមិនបាននឹងមានមិត្តរួមមនោសញ្ចេតនាត្រឹមតែម្នាក់!"

ពីក្នុងចំណោមក្រុមគ្រួសារ ពីមិត្តភក្តិរួមសាលា ពីមិត្តរួមការងារឧត្តមគតិ យើងអាចរកឃើញមិត្តរួមមនោសញ្ចេតនារបស់យើងបាន។ "អាពួកម៉ាកតាំងពីវ័យកុមាររបស់យើង" អាចជាមិត្តរួមមនោសញ្ចេតនារបស់យើង។ មិត្តរួមមនោសញ្ចេតនាពេលខ្លះ ក៏មិនមែនមិត្តរួមការងារឧត្តមគតិដែរ តែមិត្តរួមមនោសញ្ចេតនាជាមនុស្សដែលយើង និងគេយល់ចិត្តគ្នាដឹងសុខទុក្ខគ្នាទៅវិញទៅមក ជាមិត្តដែលយើងអាចចែករំលែកគ្រប់រឿងរ៉ាវជាមួយបានដោយស្ងប់ចិត្ត ដោយទុកចិត្ត និងដោយមិនរង្កៀសចិត្ត។ មានមិត្តម្នាក់បានសរសេរថា យើងអាចសម្គាល់ខ្លួនយើងបានថា តើយើងមានមិត្តរួមមនោសញ្ចេតនា ឬអត់នោះ គឺយើងអាចសម្គាល់បានពេលដែលមានរឿងរ៉ាវលំបាក មានបញ្ហាធំតូចគ្រប់បែបយ៉ាង តើយើងនឹកថាចង់ប្រាប់វាទៅកាន់នរណា? អ្នកណាដែលយើងនឹកឃើញមុនគេ? គឺមនុស្សនោះហើយជា មិត្តរួមមនោសញ្ចេតនារបស់យើង។ ហើយនៅពេលដែលយើងរីករាយ ពេលយើងសប្បាយក៏ដូចគ្នា គឺយើងនឹកចង់ចែករំលែក ភាពរីករាយ ចែករំលែកការសប្បាយនោះទៅកាន់មនុស្សម្នាក់នោះ នោះហើយជាមិត្តរួមមនោសញ្ចេតនារបស់យើង។

បើពេលយើងប្រឈមនឹងបញ្ហា ប្រឈមនឹងការលំបាក ប្រឈមនឹងសភាពតប់ប្រមល់ ការធុញទ្រាន់ក្នុងចិត្ត តែក្នុងចិត្តយើងរកមិនបានមនុស្ស ដែលយើងស្គាល់ណាម្នាក់សោះ ដែលយើងអាចចែករំលែករឿងរ៉ាវទាំងរឿងសើច ទាំងរឿងយំរបស់យើង តែយើងឱបបញ្ហា និងការលំបាក ការកង្វល់នោះតែម្នាក់ឯង នោះវាបង្ហាញថា យើងគ្មានមិត្តរួមមនោសញ្ចេតនាសូម្បីតែម្នាក់សោះឡើយ។

មិត្តរួមមនោសញ្ចេតនា ហាក់ដូចជារូបពីរ វិញ្ញាណតែមួយ។ មិត្តរួមមនោសញ្ចេតនា តែងដឹងពីសុខទុក្ខគ្នាទៅវិញទៅមក គឺគេអាចមើលឃើញការឈឺចាប់ និងទុក្ខព្រួយរបស់គ្នា ដែលទោះបីជាវាត្រូវបានបិតបាំងដោយស្នាមញញឹម ដែលស្រស់ស្អាតបំផុតក៏ដោយ។ តែការ "អាច" មើលឃើញពីបញ្ហារបស់គ្នា ដែលលាក់ក្រោមស្នាមញញឹមនោះបាន វារឹតតែស្រស់ស្អាតបំផុតលើលោកទៅទៀត។ ថ្វីត្បិតការដឹងការពិតខ្លះរវាងមិត្តរួមមនោសញ្ចេតនាវាអាចនាំឱ្យឈឺចាប់ តែនោះហើយជាភាពស្រស់ស្អាតបំផុតលើលោក ដែលយើងសំដៅដល់។ វាជារឿងអស្ចារ្យខ្លាំងណាស់ ដែលមនុស្សម្នាក់អាចចូលទៅបំពេញភាពខ្វះខាតនៅក្នុងចិត្ត របស់មិត្តបាន ថ្វីថាវាឈឺ តែវាជាការឈឺចាប់ដែលពោរពេញទៅដោយសោភ័ណ។ មនុស្សបាននាំគ្នាធ្វើដំណើរឆ្លងកាត់លោកនេះ រយពាន់ម៉ឺនលានលាននាក់រួចមកហើយ តែតើមានកំណត់ត្រាប៉ុន្មានសិប ដែលកត់ត្រាពីសោភ័ណ ដែលមើលមិនឃើញ ដោយភ្នែកទទេនេះ?

ទស្សនវិទូម្នាក់បានបន្សល់នូវគតិមួយថា "ពេលអ្នកធ្វើដំណើរលើផ្លូវឧត្តមគតិរបស់អ្នកកាន់តែយូរ កាន់តែឆ្ងាយ នោះអ្នកនឹងកាន់តែឯកោ"។ ទឹកភ្នែកបានហូរចេញពីបេះដូងរបស់ខ្ញុំ ពេលដែលនឹកឃើញដល់សភាពឯកោរបស់វីរបុរសទាំងនោះ។ តើមានអ្វីដែលកំសត់ខ្លោចផ្សារ ជាងភាពឯកោ នៅកណ្ដាលហ្វូង

មនុស្សទៀតនៅលើលោកនេះ? វាជាអារម្មណ៍ថាខ្វះជាតិទឹកក្នុងខ្លួន ខណៈដែលសំលឹងទៅរូបភាពស្ងួតក្រៀមក្រោះ ក្តៅហួតហែងនៃអាកាសធាតុ ដែលបង្ហាញដោយពន្លឺថ្ងៃចាំងទៅចំពីលើដើមឈើ ដែលត្រូវបានមនុស្សកាប់ខ្ទេច នៅសល់តែគល់។ គ្មានទឹក គ្មានដើមឈើ គ្មានផ្កា គ្មានសត្វ មានតែគល់ឈើខ្មៅៗ ដីហុយទ្រលោមស្ងួតក្រឹងតែប៉ុណ្ណោះ។ សភាពស្ងួតកនៅចំពោះមុខទិដ្ឋភាពបែបនោះយ៉ាងណា អារម្មណ៍ត្រូវការឱ្យមានលំហូរមនោសញ្ចេតនា វាពុះខ្ទោល វាប្រាលពេញរាងកាយ រត់រសិបៗតាមសរសៃឈាម ពេលដែលយើងដឹងថា មិត្តម្នាក់នោះរបស់យើងមានបញ្ហា មានការលំបាក ប៉ុន្តែយើងបែរជាចូលទៅជិតមិនបាន ដោយទទួលបានត្រឹមតែចម្លើយខ្លីៗថា "មិនអីទេ!" ក៏មានសភាពយ៉ាងនោះដែរ។ ហេតុតែចង់ឱ្យគេមិនលំបាកដោយសារខ្លួន គឺមានតែប្រាប់គេថាមិនអីទេ! តែសូមទទួលដឹងផងទៅថា ដោយអចេតនា មិត្តម្នាក់នោះ បានបន្ថែមនូវសភាពលំបាកទ្រាំនៃចិត្តឱ្យអ្នក ដែលគេមិនចង់ឱ្យលំបាកដោយសារខ្លួនទៅវិញទេ។ ការដែលបានដឹងថាមិត្តរបស់ខ្លួនមានបញ្ហាបែបនេះ ឬបែបនោះ ហើយបានដឹងថាគេបានដោះ-ស្រាយវារួចហើយ គេមិនអីទៀតទេ និងការដែលមិនដែលដឹងសោះថាគេកើតអី វាមិនដូចគ្នាទេ។ បើសិនជាសួរសុខទុក្ខគ្នាត្រឹមតែសួរឱ្យដឹងៗ វាមិនមាននាំឱ្យកើតការឈឺចាប់អ្វីឡើយ។

គំនិតដែលគិតថាលាក់ការលំបាក ឬមិនបានលាក់ទេ តែក៏មិនបានប្រាប់ មិនបានបង្ហាញនូវរាល់រឿងរ៉ាវការលំបាក បញ្ហានានាដែលយើងជួបប្រទះទៅដល់មិត្តភក្តិដោយយើងគិតថា មិនចង់នាំឱ្យគេលំបាក ដោយសារយើង វាជាសញ្ញានៃមនុស្សដែលរឹងប៉ឹង ជាសញ្ញានៃមនុស្សដែលមិនចង់ឱ្យនរណាម្នាក់លំបាក ដោយសារខ្លួន ជាសញ្ញានៃមនុស្សដែលមិនត្រូវការបន្ថែមភាពលំបាករបស់ខ្លួន ទៅលើនរណាម្នាក់ វាក៏អាចជាទម្លាប់ប្រឈមនឹងបញ្ហាតែម្នាក់ឯងតាំងតែពីដើម រហូតក្លាយទៅជាទម្លាប់ ទើបគេខាំមាត់តែម្នាក់ឯង។ ការធ្វើបែបនេះវារឹតតែបន្ថែមទំហំនៃការឈឺចាប់ ដល់អ្នកដែលជាមិត្តទៅវិញទេ។ តើវាតឹងណែនក្នុងចិត្តប៉ុណ្ណានៅពេលដែលយើងមិនអាចលូកដៃទៅជួយអ្វីសោះ ក្នុងរឿងដែលយើងអាចធ្វើវាកើត? មិត្តរួមមនោសញ្ចេតនាមិនត្រឹមតែជាមិត្ត ដែលចាំតែជួយយើង តែម្យ៉ាងនោះទេ តែគឺជាមិត្តដែលមកប្រឈម នឹងបញ្ហាជាមួយយើងតែម្តង។ ដូចបានបង្ហាញពីខាងលើរួចហើយថា វាលំបាកខ្លាំងណាស់ ដែលយើង អាចរកមនុស្សដែលមានឈាមប្រភេទដូចពួកយើង ដោយទាត់ចោលលទ្ធផលឈាមពីឡាបូវេជ្ជសាស្ត្របាន ហើយអត្រាវារឹតតែតិចទៅទៀតលើសនឹងថ្លែង នៅពេលដែលយើងទៅស្វែងរកមិត្តរួមមនោសញ្ចេតនា ពីក្នុងចំណោមមិត្តរួមឧត្តមគតិរបស់យើង។

មិត្តរួមមនោសញ្ចេតនា មិនមែនថាអាចរកបានតែពីក្នុងចំណោមមិត្តរួមឧត្តមគតិរបស់យើងទេ តែមិត្តរួមមនោសញ្ចេតនា ក៏អាចរកបានពីមនុស្សក្នុងរង្វង់សមាជិកគ្រួសារផងដែរ។ វារឹតតែប្រសើរបំផុត បើដៃគូជីវិតរបស់យើង គេជាគូជីវិតផង ជាមិត្តរួមឧត្តមគតិរបស់យើងផង ជាមិត្តរួមមនោសញ្ចេតនាផង។ ខណៈនោះពិភពលោកនេះ វាស្រស់ស្អាតបំផុតហើយ តែ

អត្រា ដែលអាចកើតឡើង សឹងតែមួយភាគលានៗ។ មិត្តរួមមនោសញ្ចេតនា ក៏អាចរកបានពីក្រុមមនុស្សរួមសង្គមដទៃទៀតដែរ។ ថ្វីថាគេមិនមែនជាមិត្តរួមឧត្តមគតិរបស់យើងក៏ដោយ តែមិត្តរួមមនោសញ្ចេតនា ជាមិត្ត ដែលយើងអាចចែករំលែក រាល់រឿងរ៉ាវជាមួយបាន។ មិត្តប្រភេទនោះ ខ្លះគ្មានកម្រិតយល់ដឹងប្រហាក់ប្រហែលយើង ដែលអាចមកជួយសម្រាលបន្ទុកបញ្ហារបស់យើងឡើយ តែគេជាមនុស្សតែម្នាក់គត់ដែលអាចទម្លុះពិភពផ្ទាល់ខ្លួនរបស់យើងបាន គេជាអ្នក ដែលយើងអាចនិយាយប្រាប់បាន គ្រប់រឿងរ៉ាវក្នុងចិត្ត មិនមែនថាប្រាប់ឱ្យគេជួយដោះស្រាយទេ តែគេជាមនុស្សដំបូងដែលយើងគិតដល់ភ្លាម ថានឹងចែករំលែកមនោសញ្ចេតនាជាមួយ។ គឺទោះពេលខ្ញុំយំក៏អ្នកដឹង ពេលខ្ញុំសើចក៏អ្នកដឹង ពេលខ្ញុំយំក្នុង សើចក្រៅក៏អ្នកដឹង។ នោះហើយគឺ មិត្តរួមមនោសញ្ចេតនា។

ចេញពីក្នុងចំណោមមិត្តរួមឧត្តមគតិ មនុស្សស្មោះត្រង់នៅត្រូវការតែការបើកចំហចិត្តតែមួយគត់ ដែលអាចនាំគេទៅរកការរកឃើញមិត្តរួមមនោសញ្ចេតនាបាន។ ដោយសាររនាំងជាច្រើនបានបិទយើង ធ្វើឱ្យយើងឈានមិនផុតពីពិភពរបស់ខ្លួនឯង។ យើងគ្រប់ៗគ្នាសុទ្ធតែមានពិភពផ្ទាល់ខ្លួន។ មានមនុស្សខ្លះប្រហែលជាអាចយល់ថា ជាការបង្ហាញថា ខ្លួនទន់ខ្សោយគ្មានសមត្ថភាព ដែលបង្ហាញប្រាប់រឿងរ៉ាវផ្ទាល់ខ្លួនទៅឱ្យមនុស្សជុំវិញដឹង។ មនុស្សខ្លះអាចគិតថាមិនចង់ឱ្យគេលំបាកដោយសារតែរឿងរបស់ខ្លួន តែមិត្តរួមមនោស-ញ្ចេតនាអាចកាប់ទម្លុះរនាំងនេះបាន។ ប៉ុន្តែដោយសារតែរនាំងនេះហើយ ដែលមិនអាចឱ្យយើងមានមិត្តរួមមនោសញ្ចេតនា។ តើរឿងបែបនេះត្រូវកាត់ចេញពីច្រកណាមុន? មនុស្សខ្លះថាចាំកាលណាគេ មានមិត្តរួមមនោសញ្ចេតនា ចាំគេប្រាប់គ្រប់រឿងទៅមិត្តរបស់គេ តែគេមិនបានដឹងទេថា ដោយសារតែការមិនបង្ហាញនោះហើយ ទើបគេគ្មានមិត្តរួមមនោសញ្ចេតនាសូម្បីតែម្នាក់សោះនោះ។

មនុស្សអាចរស់បានដោយសារមនោសញ្ចេតនា ហើយមនោសញ្ចេតនានោះ ត្រូវការឱ្យយើងមើលថែ និងផ្តល់អាហារដល់វា។ មិនថារឿងរ៉ាវសប្បាយចិត្ត ឬរឿងរ៉ាវកើតទុក្ខ ទាំងនោះហើយជាអាហារដែលទៅចិញ្ចឹមមនោសញ្ចេតនារបស់យើង។ រកបានត្រឹមតែមិត្តរួមមនោសញ្ចេតនាម្នាក់ នោះវាគ្រប់គ្រាន់ហើយសម្រាប់មួយដំណើរ នៃការមកឈានដើរហុកសិបចិតសិបឆ្នាំ លើពិភពលោកដែលមហាសែនពោរពេញទៅដោយរឿងរ៉ាវមាយាបោកប្រាស់នេះម្តង។

**តើអ្នករកមិត្តរួមមនោសញ្ចេតនារបស់អ្នកឃើញហើយឬនៅ?**

**ស្វែងយល់បន្ថែម**

(១). វិទ្យុសំបុកឃ្មុំ FM105 MHz ភ្នំពេញ: ម៉ោង ២ ដល់ម៉ោង ៣ រសៀល
(២). គេហទំព័រ: www.camldp.org
(៣). YouTube: ខឹម វាសនា ឬ Khem Veasna
(៤). Paltalk: Room Koun Khmer និង/ឬ
(៥). សារអេឡិចត្រូនិក: camldp3@gmail.com